ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ៧

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



កសវ

Work Activities

ប្រចាំខែកក្កដា ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆមាសទី១ ឆ្នាំ២០១៣ | ១ |
| ២- | ឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីសម្ពោធសមិទ្ធិផល នៅវត្តបានយ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស | ៩ |
| ៣- | ការផ្សព្វផ្សាយគម្រោងវាយតម្លៃផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត ដល់និស្សិតតាមសាកលវិទ្យាល័យ | ១២ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៤ |



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាធម្មនុញ្ញ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆមាសទី១ ឆ្នាំ២០១៣ | ១ |
| ២- | ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីសម្ពោធសមិទ្ធិផល នៅវត្តបានយ ឃុំអង្គាញ់ ស្រុកព្រៃកប្បាស | ៨ |
| ៣- | ការផ្សព្វផ្សាយគម្រោងវាយតម្លៃផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត ដល់និស្សិតតាមសាកលវិទ្យាល័យ | ១០ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១២ |

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆមាសទី១ ឆ្នាំ២០១៣



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆមាសទី១ ឆ្នាំ២០១៣នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០១៣ ដែលដឹកនាំដោយឯកឧត្តម **យឹម ឆាយលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡បើប្រៀបធៀប៦ខែដើមឆ្នាំ២០១៣និងឆ្នាំ២០១២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់**កើនឡើង ១,៩%**។ នេះគឺជាអត្រាអតិផរណាក្នុងឆមាសទី១ឆ្នាំ២០១៣ ដែលចាត់ទុកថាមានកម្រិតទាបបើធៀបនឹងទីសដៅគោលនយោបាយ៥%។

➢សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើងតែ ១% ប៉ុណ្ណោះបើធៀបនឹងឆមាសទី២ ឆ្នាំ២០១២។

តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមខែពីឆ្នាំ២០១១ដល់ឆ្នាំ២០១៣

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា$^{P}$ | សីហា$^{P}$ | កញ្ញា$^{P}$ | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ$^{P}$ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ខែដូចគ្នាឆ្នាំ | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៣,០% | ៣,១% | ៣,២% | | | | ២,៤% |
| ២០១២ | ខែដូចគ្នាឆ្នាំ | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| ២០១១ | ខែដូចគ្នាឆ្នាំ | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |

P:តួលេខខែ កក្កដា សីហាកញ្ញា និងប្រចាំឆ្នាំ២០១៣ ជាតួលេខព្យាករណ៍(តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំងអស់ទេ(មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ឆ្នាំ២០១១ ២០១២ និង២០១៣ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




តារាង២. បម្រែបម្រួលសន្ទស្សន៍ថ្លៃតាមក្រុមទំនិញវិញ

| ល.រ. | ក្រុមទំនិញ | អតិផរណា (ឆមាសទី១ ឆ្នាំ២០១៣) | អត្រារួមចំណែក (%) |
|---|---|---|---|
| ០ | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ១,៩% | ១០០% |
| ១ | ម្ហូបអាហារ | ២,៥% | ៥៧% |
| ២ | ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ២,២% | ២% |
| ៣ | សម្លៀកបំពាក់ និងស្បែកជើង | ៣,៩% | ៦% |
| ៤ | ផ្ទះសំបែងទឹកអគ្គិសនីឧស្ម័ននិងឥន្ធនៈផ្សេងទៀត | ០,៧% | ៦% |
| ៥ | គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ២,៧% | ៤% |
| ៦ | សុខាភិបាល | ១.៣% | ៣% |
| ៧ | ការដឹកជញ្ជូន<br>ក្នុងនោះ ប្រេងសាំង | -០,៩%<br>០,២% | -៦%<br>០% |
| ៨ | ទូរគមនាគមន៍ | -១,១% | -១% |
| ៩ | ការកម្សាន្ត និងវប្បធម៌ | ៤,២% | ៦% |
| ១០ | ការសិក្សា | ២,៩% | ២% |
| ១១ | ភោជនីយដ្ឋាន | ៤,១% | ១៣% |
| ១២ | ទំនិញ និងសេវាកម្មផ្សេងៗ | -០,៧% | -១% |

- ➢ មុខទំនិញដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់មានសាច់គោស្រស់ ១៤% និងបន្លែ ៥,៧% ។
- ➢ ➡អត្រាប្តូរប្រាក់ :ជារួមអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយវត្ថុបរទេសមានស្ថេរភាព។

| ប្រភេទ | ចុងឆមាសទី១ ២០១៣ | ចុងឆមាសទី១ ២០១២ | បម្រែបម្រួល |
|---|---|---|---|
| ៛/១ដុល្លារ | ៤០៦២៛ | ៤០៧៥៛ | -០,៣% |
| ៛/១បាត | ១៣១៛ | ១២៧៛ | +៣,១% |
| ៛/១ដុង | ០,១៩៣៛ | ០,១៩៤៛ | -០,៥% |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិក្នុងឆមាសទី១ ឆ្នាំ២០១៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

➢ចំណូលអនុវត្តបានចំនួន ៤២៦៩ពាន់លានរៀល ស្មើនឹង ៣៦% នៃគម្រោងប្រចាំឆ្នាំ ក្នុងនោះចំណូលចរន្តមានចំនួន ៤០៥៦ពាន់លានរៀល ស្មើនឹង ៤៩% នៃគម្រោង និងចំណូលមូលធនចំនួន ២០៧ពាន់លានរៀល។

➢បើធៀបនឹងឆមាសទី១ដូចគ្នា ឆ្នាំ២០១២ចំណូលថវិកាជាតិ កើនឡើង ១០%ដែលជាចំបងបណ្តាលមកពីចំណូលចរន្តកើនឡើង១១% ។

➢ ក្នុងចំណូលចរន្ត :ចំណូលសារពើពន្ធក្នុង៦ខែដើមឆ្នាំនេះអនុវត្តបានចំនួន៣៥៩៩ពាន់លានរៀលស្មើនឹង ៤៩% នៃគម្រោងប្រចាំឆ្នាំ។ បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១២ចំណូលសារពើពន្ធកើនឡើង ១៥% ដែលក្នុងនោះ ពន្ធនិងអាករគយ កើនឡើង ១១% និងចំណូលពន្ធដារ កើនឡើង ២១% ។

ក្រាហ្វ ២. សមាសធាតុចំណូលសារពើពន្ធ៖
ចំណូលពន្ធគយ និងចំណូលពន្ធដារ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ (ពាន់លានរៀល)

ចំណូលពន្ធគយនៅតែខ្ពស់ជាងចំណូលពន្ធដារ ប៉ុន្តែគម្លាតនៃចំណូលទាំងពីរត្រូវបានកាត់បន្ថយ។




តារាង៣.សមាសភាពនៃចំណូលចរន្ត

| មុខចំណូល | អនុវត្ត គម្រោង | %Δ ធៀបនឹង ឆ.១ឆ្នាំ២០១២ |
|---|---|---|
| **ចំណូលសារពើពន្ធ** | ៤៩% | +១៥% |
| ✓ពន្ធ-អាករគយ | ៤៩% | +១១% |
| -ពន្ធគយ (របបនាំចូល) | ៤៨% | +៨% |
| -អាករពិសេសលើរបបនាំចូល | ៤៧% | +៦% |
| -អាករលើតម្លៃបន្ថែមរបបនាំចូល | ៥២% | +១៤% |
| -អាករនាំចេញ | ៤៨% | +៣៥% |
| -អាករបន្ថែមលើផលិផលគេលសិលា | ៤៤% | 0% |
| ✓ ចំណូលពន្ធដារ | ៥៤% | +២១% |
| -ពន្ធលើប្រាក់បៀវត្ស | ៥១% | +២៥% |
| - ពន្ធលើប្រាក់ចំណេញ | ៦៣% | +២៩% |
| - ពន្ធលើឈ្នួលផ្ទះ–ដី | ៤៨% | +២២% |
| - អាករលើផលរបរ | ៣៨% | +១២% |
| - អាករលើតម្លៃបន្ថែម | ៤៦% | +១២% |
| -អាករពិសេស | ៥៥% | +១៧% |
| -ចំណូលផ្សេងៗ | ៥៣% | +៣៣% |
| -ពន្ធថវិកាខេត្ត–រាជធានី | ៥៤% | +១៧% |
| ✓ ចំណូលសារពើពន្ធផ្សេងៗ | ៥១% | +៨% |
| –កាស៊ីណូ | ៥៤% | +១១% |
| –អាជ្ញាបណ្ណក្នុងស្រុក | ៤២% | –២៦% |
| – កម្រៃគ្រប់គ្រង និងទិដ្ឋាកានាំចេញ | ៥0% | +៩% |

| មុខចំណូល | អនុវត្ត គម្រោង | %Δធៀបនឹងឆ.១ ឆ្នាំ២០១២ |
|---|---|---|
| **ចំណូលមិនមែនសារពើពន្ធ** | ៤0% | –១៤% |
| ✓នេសាទ | ៣៨% | –៦៦% |
| ✓ រុក្ខាប្រមាញ់ | — | +៤១% |
| ✓សម្បទានរ៉ែ | ១៨% | –៩៤% |
| ✓អាកាសចរណ៍ស៊ីវិល | ៥៥% | –២% |
| ✓ ផលទុនទេសចរណ៍ | ៣៨% | +៨% |
| ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៦៥% | –៣% |
| ✓អាករស្ពានទូត (លិខិតឆ្លងដែន និងទិដ្ឋាការ) | ៤៣% | –២0% |
| ✓ត្រួតពិនិត្យគុណភាពផលិតផល | ៤៧% | –២៣% |
| ✓ ជួលសហគ្រាស សម្ភារៈ | ២៧% | –២៨% |
| ✓ឯកជនភាវូបនីយកម្ម | 0% | –១00% |
| ✓លក់អចលនកម្ម | ៨២៤% | +១៥៨% |

➢ចំណាយថវិកាជាតិក្នុងឆមាសទី១ ឆ្នាំ២០១៣ អនុវត្តបានចំនួន ៣១00ពាន់លានរៀល ស្មើនឹង ២៦% នៃគម្រោងប្រចាំឆ្នាំក្នុងនោះ ចំណាយចរន្តសម្រេចបានចំនួន ២៥៩៨ពាន់លានរៀល ស្មើនឹង ៣៦% នៃគម្រោង និងចំណាយមូលធន ចំនួន ៥0២ពាន់លានរៀល ស្មើនឹង ១0% នៃគម្រោង។

➢បើប្រៀបធៀបឆមាសទី១ដូចគ្នា ឆ្នាំ២០១២ ចំណាយថវិកាជាតិកើនឡើង ១0% ក្នុងនោះចំណាយចរន្តកើនឡើង ៥% និងចំណាយមូលធនកើនឡើង ៤0%។

➢ថវិកាជាតិនាឆមាសទី១ឆ្នាំ២០១៣ មានអតិរេកចំនួន ១១៦៩ពាន់លានរៀល ស្មើនឹង ២៩២ លានដុល្លារ ស.រ.អា។

## ៣)ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុនាចុងឆមាសទី១ឆ្នាំ២០១៣មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ M2 មានចំនួន ៣១៦៥៩ពាន់លានរៀល កើនឡើង ១៩% ធៀបនឹងឆមាសទី១ ឆ្នាំ២០១២។

➢ការកើនឡើងនៃ M2 នេះបណ្តាលមកពីកំណើននៃរូបិយវត្ថុក្រៅធនាគារ១៧% ប្រាក់បញ្ញើចរន្ត ៤៥% និងប្រាក់បញ្ញើជារូបិយបណ្ណ ២០%។ គួរកត់សម្គាល់ថា ប្រាក់បញ្ញើមានកាលកំណត់និងសន្សំថយចុះ៧%។

➢ចំនួនប្រាក់រៀលនៅក្នុង និងក្រៅធនាគារសរុបមានចំនួន១៦,៩% នៃរូបិយវត្ថុ M2រីឯប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,១%។

ក្រាហ្វ៣.សមាសធាតុរូបិយវត្ថុកម្ពុជានាចុងឆមាសទី១ ឆ្នាំ២០១៣




➢ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធមានចំនួន ៣៤៤៨លានដុល្លារ កើនឡើង១០% ធៀបនឹងឆមាសទី១ ឆ្នាំ២០១២ ។

➢ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជា ជាទូទៅមានការកើនឡើង។ ក្នុងឆមាសទី១ឆ្នាំ២០១៣សូចនាករណ៍នេះមានចំនួន ៩៧៩១ ពាន់លានរៀល កើនឡើង ៨% បើធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០១២។

➢ការផ្តល់ឥណទានដោយធនាគារពាណិជ្ជមានចំនួន ២៩៤៩៤ពាន់លានរៀលកើនឡើង ៤៥% ធៀបនឹងឆមាសទី១ ឆ្នាំ២០១២ ។

➢ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៤៤៥៩ ពាន់លានរៀល កើនឡើង៥០% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១២។

➢*អត្រាការប្រាក់ប្រចាំឆ្នាំ៖*

| ប្រភេទអត្រាការប្រាក់ | ចុងឆមាសទី១ ឆ្នាំ២០១៣ | ចុងឆមាសទី១ ឆ្នាំ២០១២ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៨% | ៥,៨១% | +៣% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៩៣% | ១២,១២% | -២% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៣% | ៤,៤១% | +0,៤% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៧១% | ១២,៦៣% | -៧% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

ក្នុងឆមាសទី១ ឆ្នាំ២០១៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➡កសិកម្ម៖

➢ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ (២០០៨-២០១២) ផលិតផលស្រូវកើនឡើងជាមធ្យម៧% ក្នុងមួយឆ្នាំ។ មកដល់ចុងឆមាសទី១ ឆ្នាំ២០១៣ ផ្ទៃដីដាំស្រូវមានចំនួន ៦៧៤,0ពាន់ហិកតា ថយចុះ ២០១ពាន់ហិកតា បើធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំ២០១២។ តារាងខាងក្រោមបង្ហាញផ្ទៃដីដំណាំ ដែលបានដាំក្នុង៦ខែដើមឆ្នាំ២០១៣។

| *ប្រភេទដំណាំ* | *ឆមាសទី១-២០១៣* | *ឆមាសទី១-២០១២* | ឆ្នាំ២០១២ |
|---|---|---|---|
| ផ្ទៃដីដាំស្រូវវស្សា (ពាន់ហិកតា) | ៦៧៤,0 | ៨៧៥,0 | ២៥១៣ |
| ផ្ទៃដីដាំពោត (ពាន់ហិកតា) | ៩៨,១ | ៧៩,៧ | ២១៥,៤ |
| ផ្ទៃដីដាំដំឡូងឈើ (ពាន់ហិកតា) | ៣១១,១ | ២៤៥,0 | ៣៣៧,១ |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

ក្នុងឆមាសទី១ ឆ្នាំ២០១៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

**➡កសិកម្ម៖**

➢ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ (២០០៨-២០១២) ផលិតផលស្រូវកើនឡើងជាមធ្យម៧% ក្នុងមួយឆ្នាំ។ មកដល់ចុងឆមាសទី១ ឆ្នាំ២០១៣ ផ្ទៃដីដាំស្រូវមានចំនួន ៦៧៤,០ពាន់ហិកតា ថយចុះ ២០១ពាន់ហិកតា បើធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំ២០១២។ តារាងខាងក្រោមបង្ហាញផ្ទៃដីដំណាំ ដែលបានដាំក្នុង៦ខែដើមឆ្នាំ២០១៣។

| ប្រភេទដំណាំ | ឆមាសទី១ -២០១៣ | ឆមាសទី១-២០១២ | ឆ្នាំ២០១២ |
|---|---|---|---|
| ផ្ទៃដីដាំស្រូវវស្សា (ពាន់ហិកតា) | ៦៧៤,០ | ៨៧៥,០ | ២៥១៣ |
| ផ្ទៃដីដាំពោត (ពាន់ហិកតា) | ៩៨,១ | ៧៩,៧ | ២១៥,៤ |
| ផ្ទៃដីដាំដំឡូងឈើ (ពាន់ហិកតា) | ៣១១,១ | ២៤៥,០ | ៣៣៧,១ |
| ផ្ទៃដីដាំដំឡូងជ្វា (ពាន់ហិកតា) | ៣,០ | ២,៩ | ១០,២ |
| ផ្ទៃដីដាំបន្លែគ្រប់មុខ (ពាន់ហិកតា) | ១៨,៦ | ២១,២ | ៧៦,១ |
| ផ្ទៃដីដាំសណ្តែកបាយ (ពាន់ហិកតា) | ៣៨,៧ | ៣៩,៣ | ៦៧,៥ |
| ផ្ទៃដីដាំសណ្តែកដី (ពាន់ហិកតា) | ១៣,៣ | ១១,៣ | ១៨,៣ |
| ផ្ទៃដីដាំសណ្តែកសៀង (ពាន់ហិកតា) | ១,៥ | ០,៣ | ៧១,៧ |

➢ ផលិតផលនេសាទមានចំនួន **២៧៨,៥ពាន់តោន** ថយចុះ ៣៤% បើធៀបនឹងឆមាសទី១ដូចគ្នា ឆ្នាំ២០១២។

**➡ឧស្សាហកម្ម៖**

➢ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១៨៤៥,៨GWh កើនឡើង ២០% ធៀបនឹងឆមាសទី១ ឆ្នាំ២០១២។ ក្នុងនោះ វារីអគ្គិសនីមានចំនួន ១២២,៧GWh កើនឡើង ២៧%។

➢ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ២៣០១,៤លានដុល្លារ កើនឡើង ១៤% ធៀបនឹងឆមាសទី១ ឆ្នាំ២០១២។

➢ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន :ឆមាសទី១ ឆ្នាំ២០១៣ | ចំនួន:ឆមាសទី១ ឆ្នាំ២០១២ | បម្រែបម្រួល |
|---|---|---|---|
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ៨៨ | ៨៣ | +៦% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១១៤ | ១០៤ | +១០% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៥៩ | ៤១ | +៤៤% |

**➡សំណង់៖**

➢សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៤៨៧២ពាន់ម$^2$ កើនឡើង ៨០% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១២។ ការអនុញ្ញាតនេះ ជាទឹកប្រាក់មានចំនួន ១៩៣៧លានដុល្លារ កើនឡើង ១២៣% បើធៀបនឹង៦ខែដើមឆ្នាំ២០១២។ ក្នុងនោះប្រភេទសំណង់សំខាន់ៗមាន៖

| *ប្រភេទសំណង់* | ពាន់ម$^2$ :ឆមាសទី១ ឆ្នាំ២០១៣ | ពាន់ម$^2$ :ឆមាសទី១ ឆ្នាំ២០១២ | បម្រែបម្រួល |
|---|---|---|---|
| លំនៅឋាន | ៨៨៧,៥ | ៩១៧,៣ | -៣% |
| ឧស្សាហកម្ម | ៤២៦,២ | ៩៦០,៨ | -៥៦% |
| ពាណិជ្ជកម្ម | ៣១៣៥ | ៣៩១,១ | +៧០២% |
| ទេសចរណ៍ | ១៤៧,៥ | ៣០៨,៣ | -៥២% |
| ... | | | |
| អនុញ្ញាតសរុប | ៤៨៧២ | ២៧០៩ | +៨០% |

➢ **ដូច្នេះ**ក្នុងការអនុញ្ញាតឆមាសទី១ ឆ្នាំនេះ សំណង់ដែលពេញនិយមគឺពាណិជ្ជកម្ម (៦៤% នៃផ្ទៃក្រឡាសរុប) លំនៅឋាន ១៨% និងឧស្សាហកម្ម (៩% នៃផ្ទៃក្រឡាសរុប)។

**➡ការងារ៖**

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៣ (នាក់) | ឆមាសទី១ ឆ្នាំ២០១២ (នាក់) | បម្រែបម្រួល |
|---|---|---|---|
| អ្នកដាក់ពាក្យរកការធ្វើទៅក្រៅប្រទេស | ៨៩៦១ | ១៣៣៨៤ | –៣៣% |
| អ្នកទទួលបានការធ្វើតាមរយៈក្រសួងនិងក្រុមហ៊ុន | ១៥៣៦៩ | ២១៨៦៧ | –៣០% |
| អ្នកទទួលបានការធ្វើក្នុងប្រទេស | ៧៨៨៩ | ១១០៩៦ | –២៩% |
| អ្នកទទួលបានការធ្វើក្រៅប្រទេស | ៧៤៨០ | ១០៧៧១ | –៣១% |

**➡វិនិយោគ៖**

➢គម្រោងវិនិយោគ**អនុញ្ញាតដោយ** ក.អ.ក. (ថ្មី និងពង្រីក) មានចំនួន ៧៣ គម្រោង (ឆមាសទី១ ឆ្នាំ ២០១២ មានចំនួន ១០៩គម្រោង) ។ ជាទុនវិនិយោគ ការអនុញ្ញតមានទឹកប្រាក់ចំនួន ២៣៦៦,៧លានដុល្លារ កើនឡើង៨៥% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១២។គម្រោងទាំងនេះអាចបង្កើតការងារបាន **១១១ពាន់នាក់**។

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៣ | ឆមាសទី១ ឆ្នាំ២០១២ | បម្រែបម្រួល |
|---|---|---|---|
| **អនុញ្ញាតសរុប** (លានដុល្លារ) ក្នុងនោះ : | ២៣៦៦,៧ | ១២៧៧,២ | +៨៥% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៧៦,៤ | ២៧០,៩ | –៧២% |
| វិស័យឧស្សាហកម្ម | ៣៩៣,១ | ៩៣៧,៤ | –៥៨% |
| ក្នុងនោះ: តំបន់សេដ្ឋកិច្ចពិសេស | ២២,២ | ៣៨២,៤ | –៩៤% |
| វិស័យទេសចរណ៍ | ១០៦ | ៥០,៩ | +១០៨% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១៧៩១,២ | ១៨ | +៩៨៥១% |
| **គម្រោងថ្មី និងគម្រោងពង្រីក (ចំនួន)** | ៧៣ | ១០៩ | –៣៣% |
| **បង្កើតការងារ (ពាន់នាក់)** | ១១១ | ១៧០ | –៣៥% |

**➡សេវាកម្ម និងទេសចរណ៍៖**

➢ការចុះបញ្ជី និងលុបចេញពីបញ្ជី៖

| *ប្រភេទ* | *ចំនួន* :ឆមាសទី១ ឆ្នាំ២០១៣ | *ចំនួន* :ឆមាសទី១ ឆ្នាំ២០១២ | បម្រែបម្រួល |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១៣៦៨ | ១៦៩៤ | –១៩% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៦ | ២១ | –៧១% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៨១៤ | ១២០៧ | –៣៣% |

| | | | |
|---|---|---|---|
| ស៊ីម៉ង់ត៍ | +១៥% | គេសជ្ជៈ | +៤៣% |
| គ្រឿងអេឡិចត្រូនិក | −១៣% | បារី | −៥% |
| រថយន្តសរុប (ជា ព.ល.រ)<br>រថយន្តសរុប (ជាគ្រឿង) | +៣%<br>−៣% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៤៧% |

➡**ការនាំចេញ** ក្នុងឆមាសទី១ ឆ្នាំ២០១៣ មានចំនួន ១២៨០៦ពាន់លានរៀល កើនឡើង ២៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០១២។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | %△ធៀបនឹងឆ.ទី១ ឆ្នាំ២០១២ | ទំនិញ | %△ធៀបនឹងឆ.ទី១ ឆ្នាំ២០១២ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៨៣% | ផលិតផលនេសាទ | −៧២% |
| វាយនភណ្ឌនិងស្បែកជើង | +១៧% | កៅស៊ូ | +២៩% |
| អង្ករ | +១២៣% | | |

➡ក្នុងឆមាសទី១ ឆ្នាំ២០១៣ **ជញ្ជីងពាណិជ្ជកម្ម** មានឱនភាព **៥២៤៩ ពាន់លានរៀល** ស្មើនឹង **១៣១២** លានដុល្លារ ស.រ.អា ។ យោងតាមតួលេខ ជញ្ជីងពាណិជ្ជកម្ម តែងតែមានឱនភាពធំ ក្នុងឆមាសទី១ ជាងក្នុងឆមាសទី២។

## ៦)ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុង*ឆមាសទី១ ឆ្នាំ២០១៣* សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ឆមាសទី១ ឆ្នាំ២០១៣ | %△ធៀបនឹងឆមាស១ ឆ្នាំ២០១២ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់គោស្រស់ | ១៨៧%<br>ធៀបនឹងថ្លៃក្នុងត្រីមាសទី៣ឆ្នាំ២០០៦ | +១៤% | — |
| ២ | ចំណូលមិនមែនសារពើពន្ធ | ៤៥៦,៣ ពាន់លានរៀល | −១៤% | — |
| ៣ | ផលិតកម្មនេសាទ | ២៧៨,៥ ពាន់តោន | −៣៤% | ការបិទឡូនេសាទ |

## ៧)ស្មារតីអង្គប្រជុំ និងសន្និដ្ឋាន

### *អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១) អត្រាអតិផរណាក្នុងឆ្នាំ២០១៣នឹងស្ថិតក្នុងកម្រិតទាបជាង ៥% ទោះជាមានការរំពឹងថាអត្រាអតិផរណាក្នុងឆមាសទី២មានការកើនឡើងក៏ដោយ។ ប៉ុន្តែមានមុខទំនិញមួយចំនួនមានការឡើងថ្លៃខ្ពស់គួរឲ្យកត់សម្គាល់ ដូចជាសាច់គោស្រស់ ផ្លែឈើ និងបន្លែ។

២) ចំណូលពន្ធដារមានកំណើនគួរឲ្យកត់សម្គាល់ ប៉ុន្តែអាចនឹងថយចុះក្នុងឆមាសទី២ ឆ្នាំ២០១៣។

៣) ការដកប្រាក់បញ្ញើមានការកើនឡើង ជាពិសេសប្រាក់បញ្ញើជារូបិយបណ្ណក្នុងចុងឆមាសទី១ ។

៤) ដោយបង្កើនការទប់ស្កាត់បទល្មើសនេសាទ មានការរំពឹងថាផលិតផលនេសាទនឹងសម្រេចបានកម្រិតខ្ពស់ក្នុងឆមាសទីពីរ។

### *សេចក្តីសន្និដ្ឋាន៖*

សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជានាឆមាសទី១ ឆ្នាំ២០១៣ សម្រេចបានលទ្ធផលវិជ្ជមានមួយចំនួនដូចជា វិស័យវាយនភណ្ឌ សំណង់ និងទេសចរណ៍ បានបង្ហាញកំណើនធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ យ៉ាងណាមិញ សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនផងដែរដូចជា ការថយចុះនៃទុនវិនិយោគបរទេសតាមវិស័យផលិតកម្ម (តួលេខទុនវិនិយោគក្នុងឆមាសទី១ ឆ្នាំ២០១៣នេះ ជារួមគឺទៅលើហោដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះ) ការធ្លាក់ចុះនៃការចុះបញ្ជីពាណិជ្ជកម្ម និងបញ្ជីបង់ពន្ធដាររបស់សហគ្រាសធុរកិច្ច កំណើននៃការនាំចេញផលិតផលវាយនភណ្ឌនិងស្បែកជើងនៅមានកម្រិតទាប និងការថយចុះនូវការចិញ្ចឹមសត្វ ដូចជាគោ ក្របី ជ្រូកជាដើម។

# ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ក្នុងពិធីសម្ពោធសមិទ្ធផលនៅវត្តបានយ ឃុំអង្គាញ់ ស្រុកព្រៃកប្បាស

កាលពីព្រឹកថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានា ក្នុងវត្តបានយ ស្ថិតក្នុងឃុំអង្គាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។






លោក **អ៊ិត សារ** អភិបាលស្រុកព្រៃកប្បាស បានឲ្យដឹងថា ស្រុកព្រៃកប្បាសមានវត្តចំនួន ៣១ ក្នុងនោះវត្តធម្មយុត្តិកនិកាយមានចំនួន២។ ព្រះសង្ឃសរុប ២៧០អង្គ ក្នុងនោះសាមណេ ១៥០អង្គ និងភិក្ខុ ១២០អង្គ។ ពុទ្ធិកបឋម សិក្សាមាន ០៦កន្លែង មានសមណសិស្ស២២៧អង្គ។

ឯកឧត្តម **យឹម ណុលឡា** បានមានប្រសាសន៍នៅក្នុងឱកាសនោះថា ពួកប្រល័យពូជសាសន៍ ប៉ុលពត បានបំបាត់មិនឲ្យមានសាលា និងបំផ្លិចបំផ្លាញគ្រប់ហេដ្ឋារចនាសម្ព័ន្ធរបស់ជាតិស្ទើរគ្មានសល់។ ព្រះសង្ឃ និងបុព្វជិត នៅទូទាំងប្រទេស ត្រូវបណ្ដេញចេញពីគ្រប់វត្តអារាមយ៉ាងឃោរឃៅ ហើយថែមទាំងត្រូវបានចាប់ផ្សឹកយ៉ាងព្រៃផ្សៃ និងបង្ខំឲ្យធ្វើការជាទម្ងន់ ព្រះសង្ឃ និងបុព្វជិតមួយចំនួនធំត្រូវបាន ធ្វើគតថែមទៀតផង។ វត្តអារាមមួយចំនួនធំត្រូវបានកម្ទេចចោល និងវត្តដែលនៅសេសសល់ ត្រូវបានពួកអាវខ្មៅប្រែក្លាយជាមន្ទីរឃុំឃាំង ជាកន្លែងចិញ្ចឹមជ្រូក និងសត្វពាហនៈជាដើម។ ប៉ុន្តែពួកគេមិនអាចលុបបំបាត់ជំនឿរបស់ប្រជាជនកម្ពុជាលើ ព្រះពុទ្ធសាសនាបានឡើយ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** បានថ្លែងបន្តថា ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ សាសនាទាំងអស់នៅកម្ពុជាបានរស់ឡើងវិញ។ ហើយសាសនាពិតជាបានរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងភាពសុខដុមរមណីកម្ម ក្នុងសង្គមមួយប្រកបដោយភាពសុខសាន្តនិងគ្នា ហើយបានដើរលើផ្លូវតែមួយ ក្រោមដំបូលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបានកំពុងដើរតួនាទីយ៉ាងសំខាន់សម្រាប់ឯកភាពជាតិ ការពារ បូរណភាពទឹកដី ការសិក្សាអប់រំ និងការរក្សាអត្តសញ្ញាណរបស់ជាតិ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ក៏បានថ្លែងផងដែរថា សមិទ្ធិផលដែលរៀបចំពិធីសម្ពោធកាលពីថ្ងៃទី២៣ ខែមិថុនា រួមមានអគារសិក្សាវិទ្យាល័យមួយខ្នង ៥បន្ទប់ ជណ្តើរស្រះទឹក ប្រាង្គប្រាសាទ និងសួនទេវទូត ដែលចំណាយទឹកប្រាក់ ៨៩.៥២៨ដុល្លារ ដែលជាអំណោយប្រកបដោយបុណ្យកុសលរបស់លោក ជ អូន និងអ្នកស្រី ជួន ទៀង និងពុទ្ធបរិស័ទចំណុះជើងវត្ត ព្រមទាំងសប្បុរសជនក្នុង និងក្រៅប្រទេស។

សមិទ្ធិផលទាំងនេះ បានឆ្លុះបញ្ចាំងនូវការរីកចម្រើនរបស់វត្តបានយថែមទៀត និងឆ្លុះបញ្ចាំងនូវវឌ្ឍនភាពនៃវិស័យព្រះពុទ្ធសាសនា និងការលើកកម្ពស់សកម្មភាពចូលរួមដល់ការពង្រឹងវិស័យព្រះពុទ្ធ សាសនាដែលជាផ្នែកមួយដ៏សំខាន់ នៃ វប្បធម៌ជាតិ ក្រោមគោលនយោបាយអភិវឌ្ឍន៍សង្គមនៃរាជរដ្ឋាភិបាល ដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។





ពាក់ព័ន្ធនិងការបោះឆ្នោតដែលឈានមកដល់នាពេលខាងដ៏ខ្លីនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ក៏មិនភ្លេចផងដែរ ជាមួយនិងការផ្តាំផ្ញើ ព្រមទាំងនិមន្ត និងអញ្ជើញព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរទាំងអស់ អញ្ជើញទៅបោះឆ្នោតបោះឆ្នោតដើម្បីសម្រេចជោគវាសនារបស់ខ្លួន។

ក្នុងឱកាសសម្ពោធដ៏ច្រើនក្នុងវត្តបានយ ឯកឧត្តមទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** បានបំពាក់គ្រឿងឥស្សរិយយស មេដាយ និងលិខិតសរសើរ ប្រគេនថ្វាយ និងជូនសប្បុរសជន ដែលបានចំណាយថវិកាដើម្បីកសាងវត្តបានយ ក្នុងនោះរួមមាន៖ ព្រះតេជគុណ រស់ សុខា ព្រះចៅអធិការវត្តបានយ គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេនា, លោក ជ អូន គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាថ្នាក់ធិបឌិន, លោក អ៊ុយ ជ្រៃ មេដាយមាសស្ថាបនាជាតិ និង គង់ សុវណ្ណ មេដាយប្រាក់ស្ថាបនាជាតិ។ ក្នុងនោះក៏មានប្រគល់លិខិតសរសើរដល់ លោក ជ អូន លោក ជ ស៊ា លោកស្រី គង់ ម៉េង លោកស្រី សា រឿន លោក កាង កុង និង លោក ឈឹម ហ៊ុច។

# ការផ្សព្វផ្សាយគម្រោងវាយតម្លៃផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត ដល់និស្សិតតាមសាកលវិទ្យាល័យ

នៅព្រឹកថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០១៣ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) សហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំសិក្ខាសាលាស្តីពីការយល់ដឹងជាសាធារណៈ លើការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិ នៅសកលវិទ្យាល័យពុទ្ធិសាស្ត្រ ។

សិក្ខាសាលានេះនឹងធ្វើបទបង្ហាញជូនដល់សាស្ត្រាចារ្យ និងនិស្សិត ជាង ២០០នាក់ ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលសន** អនុប្រធាន ECOSOCC និងជានាយកគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត តំណាង ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន ECOSOCC ព្រមទាំងមានការអញ្ជើញចូលរួមជាវាគ្មិន ដោយឯកឧត្តម **សុខ ពុទ្ធិវុធ** សកលវិទ្យាធិការ នៃវិទ្យាល័យពុទ្ធិសាស្ត្រ ។

ការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្តិ គឺជាការវិភាគមានលក្ខណៈជាប្រព័ន្ធលើសំណើបញ្ញត្តិកម្ម ជាឧបករណ៍ និងជាវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់សម្រាប់ការព្រាងសំណើបញ្ញត្តិកម្មឲ្យប្រសើរឡើង ដោយផ្តល់ព័ត៌មានពីបន្ទុកចំណាយ និងផលចំណេញបានច្បាស់លាស់ ជូនថ្នាក់ដឹកនាំសម្រេច ដើម្បីលើកកម្ពស់គោលនយោបាយប្រកួតប្រជែង ព្រមទាំងអភិបាលកិច្ចល្អ ។ នៅប្រទេសកម្ពុជា ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត អាស្រ័យលើការវិភាគដោយផ្អែកលើសុភវិនិច្ឆ័យ និងកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ។





គម្រោង RIA នេះ ជាផ្នែកមួយនៃការខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការកំណែទម្រង់លើគ្រប់វិស័យដែលធ្វើឲ្យសម្រេចបាននូវសន្តិសុខសង្គម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ គម្រោង RIA នេះ មានទីភ្នាក់ងារប្រតិបត្តិគម្រោង (ហៅថា EA) ស្ថិតនៅក្រោម ECOSOCC ដែលជាអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី

និងមានក្រសួងពាក់ព័ន្ធចំនួន ៤ចូលរួម ជាទីភ្នាក់ងារអនុវត្តគម្រោង (ហៅថា IA) រួមមានក្រសួងពាណិជ្ជកម្ម ក្រសួង បរិស្ថាន ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងក្រសួងទេសចរណ៍ ។

គម្រោង RIA បាន និងកំពុងដំណើរការបានល្អគួរឲ្យកត់សម្គាល់ ចាប់តាំងពីពេលចាប់ផ្តើមនៅខែតុលា ឆ្នាំ២០១១មក ។ របាយការណ៍ចាប់ផ្តើមគម្រោង ដែលបង្ហាញពីផែនការសម្រាប់ការអនុវត្តគម្រោង RIA សៀវភៅស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា (Manual/Guideline) ទម្រង់នៃការវាយតម្លៃបឋម (PAS) និងបញ្ជីត្រួតពិនិត្យ (Checklist) ត្រូវបានបោះពុម្ពផ្សាយជាភាសាអង់គ្លេស និង ភាសាខ្មែរ ។





សកម្មភាពសំខាន់ៗនៃគម្រោង គឺការកសាងសមត្ថភាពមន្ត្រីគម្រោង តាមការបណ្តុះបណ្តាលដោយអ្នកជំនាញរបស់ក្រុមទីប្រឹក្សានៃក្រុមហ៊ុន POHL ។ ក្រៅពីទម្រង់បណ្តុះបណ្តាលខាងលើ មានការសិក្សាដកបទពិសោធន៍នៅក្រៅប្រទេស ដូចជា ប្រទេសអូស្ត្រាលី និងប្រទេសអង់គ្លេសបន្ថែមទៀត ដើម្បីឲ្យឃើញដោយផ្ទាល់នូវការអនុវត្តរបស់ប្រទេសអភិវឌ្ឍន៍។ ជាលទ្ធផលកន្លងមក គឺក្រសួងដែលជាភ្នាក់ងារអនុវត្តគម្រោងសម្រេចបានរបាយការណ៍វាយតម្លៃបឋម (PAS) ចំនួន ១៥ ដោយមានជំនួយពីមន្ត្រី ECOSOCC និងក្រុមទីប្រឹក្សាអន្តរជាតិ របស់ក្រុមហ៊ុន POHL ។ ចាប់ពីត្រីមាសទី១ ឆ្នាំ ២០១៣ មន្ត្រីគម្រោងនៃក្រសួងដែលជាភ្នាក់ងារអនុវត្តគម្រោង និងធ្វើរបាយការណ៍វាយតម្លៃបឋម រឺរបាយការណ៍វាយតម្លៃពេញលេញដោយខ្លួនឯង ដោយមានជំនួយពីមន្ត្រីគម្រោង RIA នៅ ECOSOCC ។

ក្រៅពីសកម្មភាពខាងលើ គម្រោង RIA បានធ្វើការផ្សព្វផ្សាយជាសាធារណៈស្តីពីវិធីសាស្ត្រ RIA ដល់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សាអាជ្ញាធរពាក់ព័ន្ធ គ្រឹះស្ថានឧត្តមសិក្សាជាន់ខ្ពស់ វិស័យឯកជន-អ្នកធុរកិច្ច និងសង្គមស៊ីវិលជាច្រើន ។ ជាពិសេសគឺកម្មវិធីផ្សព្វផ្សាយគម្រោង RIA ដែលបានប្រារព្ធទៅកាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីបណ្ឌិតសាស្ត្រាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ADB មួយចំនួន ៕

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៣

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៧/១៣<br>ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៧/០៧/១៣<br>ម៉ោង ១៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរខួបលើកទី៥ នៃការចុះបញ្ជីប្រាសាទព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានជាតិអូឡាំពិក។ |
| ៣ | ០៩/០៧/១៣<br>ម៉ោង ០៩ : ០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **កែវ រ៉េមី** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១០/០៧/១៣<br>ម៉ោង ០៨ : ០០នាទី | ចូលរួមប្រជុំពិភាក្សាការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជធានីភ្នំពេញ។ |
| ៥ | ១១/០៧/១៣<br>ម៉ោង ១៥:៣០នាទី | ចូលរួមប្រជុំពិភាក្សាការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅបាទី។ |
| ៦ | ១៤/០៧/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមគោរពវិញ្ញាណក្ខន្ធ អ្នកឧកញ៉ាមហាភក្តីសប្បុរិសភោគាធិបតី **ហ៊ុន នាង** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជធានីភ្នំពេញ។ |
| ៧ | ១៧/០៧/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមក្នុងពិធីបញ្ចុះសព អ្នកឧកញ៉ាមហាភក្តីសប្បុរិសភោគាធិបតី **ហ៊ុន នាង** នៅវត្តព្រះបារមីវង្គដ្ឋបូរី ក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ។ |
| ៨ | ១៩/០៧/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសែរ៉ា ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៣

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៧/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សា ២ខ្នង វិទ្យាល័យ សុខ អាន ក្តីទន្ទឹម ឃុំជើងកូន ស្រុកសំរោង ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅឃុំជើងកូន ស្រុកសំរោង ខេត្តតាកែវ។ |
| ២ | ០៥/០៧/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សា អគារសម្ភព និងសាលាធម្មសភា នៅឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវិទ្យាល័យ សុខ អាន ដូងខ្ពស់បូរជលសារ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ។ |
| ៣ | ១១/០៧/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធសាលាធម្មសភា និងសមិទ្ធផលនានា ក្នុងវត្តឈើទាលជ្រុំ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅក្នុងវត្តឈើទាលជ្រុំ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ។ |
| ៤ | ១៩/០៧/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសៃវ៉ា ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ៥ | ២៣/០៧/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តមង្គលមានលក្ខ ភូមិត្រពាំងគល់ ឃុំត្រពាំងធំខាងជើងស្រុកត្រាំកក់ ខេត្តតាកែវ។ |
| ៦ | ២៦/០៧/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្ត អាណត្តិទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីធ្លាមុខសាលមហាស្រុកខេត្តតាកែវ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៣

## ឯកឧត្តម ឌុយ ឆៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៧/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សា ២ខ្នង វិទ្យាល័យ សុខ អាន ក្តីទន្ទឹម ឃុំជើងកូន ស្រុកសំរោង ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅឃុំជើងកូន ស្រុកសំរោង ខេត្តតាកែវ។ |
| ២ | ០៥/០៧/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សា អគារសម្ពុត និងសាលាធម្មសភា នៅឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវិទ្យាល័យ សុខ អាន ដូងខ្ពស់បូរជលសារ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ។ |
| ៣ | ១១/០៧/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធសាលាធម្មសភា និងសមិទ្ធផលនានា ក្នុងវត្តឈើទាលជ្រុំ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅក្នុងវត្តឈើទាលជ្រុំ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ។ |
| ៤ | ១៩/០៧/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសែរ៉ា ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ៥ | ២៣/០៧/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តមង្គលមានលក្ខ ភូមិត្រពាំងគល់ ឃុំត្រពាំងធំខាងជើងស្រុកត្រាំកក់ ខេត្តតាកែវ។ |
| ៦ | ២៦/០៧/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីធ្លាមុខសាលមហាស្រុកខេត្តតាកែវ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៣

## ឯកឧត្តម ម៉ាន់ គិរុណា អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៧/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សា ២ខ្នង វិទ្យាល័យ សុខ អាន ក្តីទន្ទឹម ឃុំជើងកូន ស្រុកសំរោង ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅឃុំជើងកូន ស្រុកសំរោង ខេត្តតាកែវ។ |
| ២ | ០៥/០៧/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សា អគារសម្ភព និងសាលាធម្មសភា នៅឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវិទ្យាល័យ សុខ អាន ដូងខ្ពស់បូរជលសារ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ។ |
| ៣ | ១១/០៧/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធសាលាធម្មសភា និងសមិទ្ធផលនានា ក្នុងវត្តឈើទាលជ្រុំ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅក្នុងវត្តឈើទាលជ្រុំ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ។ |
| ៤ | ១៩/០៧/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសៅរ៉ា ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ៥ | ២៣/០៧/១៣ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តមង្គលមានលក្ខ ភូមិត្រពាំងគល់ ឃុំត្រពាំងធំខាងជើងស្រុកត្រាំកក់ ខេត្តតាកែវ។ |
| ៦ | ២៦/០៧/១៣ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីធ្លាមុខសាលមហាស្រុកខេត្តតាកែវ។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡែន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ថាន់ គិរុណា | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង រត្នមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ឆារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត ភក្កដា | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in